**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-May-2011, 08:42
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

**សំណុំរឿងលេខ:** ០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស

**ភាគីដាក់ឯកសារ:** សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

**ដាក់ជូន:** អង្គបុរេជំនុំជម្រះ

**ភាសាដើម:** អង់គ្លេស

**កាលបរិច្ឆេទឯកសារ:** ថ្ងៃទី១២ ខែ ឧសភា ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

**ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈ

**ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:**

**ឈ្មោះមន្ត្រីកត់ត្រា:**

---

**សំណើសុំពន្យារពេលបរិច្ឆេទកំណត់សម្រាប់ការដាក់បណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាស្តីពីភាពអាចទទួលយកបានចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក ROBERT HAMILL ក្នុងពេលកំពុងរង់ចាំការអនុញ្ញាតឲ្យចូលមើលសំណុំរឿងក្តី**

---

<u>ដាក់ជូនដោយ:</u> <u>ផ្ញើជូន:</u>

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី:**

**អង្គបុរេជំនុំជម្រះ:**
ចៅក្រម ប្រាក់ គឹមសាន

លោក សំ សុគង់ ចៅក្រម ន័យ ថុល

លោកស្រី Lyma NGUYEN ចៅក្រម ហួត វុទ្ធី

ចៅក្រម Catherine MARCHI-UHEL

ចៅក្រម Rowan DOWNING

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Siegfried BLUNK

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew T. CAYLEY

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

លោក ហុង គីមសួន

លោកស្រី Silke STUDZINSKY

លោក ជួង ជូងី

## សំណើជាបន្ទាន់សុំពន្យារកាលបរិច្ឆេទកំណត់សម្រាប់ការដាក់ជូនសារណា

១. នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ លោក Rob HAMILL (11-VSS-00002) អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានសម្រេចដោយសហចៅក្រមស៊ើបអង្កេតតាមរយៈដីកាសហចៅក្រម (ឯកសារលេខD១១/២/៣) ថាមិនអាចទទួលយកបាននៅក្នុងសំណុំរឿងក្តី០០៣ ទេ។ គាត់ក៏ត្រូវបានបដិសេធយ៉ាងជាក់ស្តែងនៅក្នុងសំណុំរឿង ០០៤ ( D5/2/3, ដីកាស្តីពីភាពអាចទទួលយកបានដែលដីកានេះមិនត្រូវបានជូនដំណឹង ហើយក៏មិនត្រូវបានទទួលដោយអ្នកដាក់សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឬមេធាវីរបស់គេនោះទេ[1]។

២. នៅថ្ងៃទី១២ ឧសភា ២០១១ លោក HAMILL បានទទួលឯកសារ D11/2/3 តាមរយៈសំបុត្រប្រៃសនីយនៅឯអាស័យដ្ឋានរបស់គាត់ក្នុងប្រទេស New Zealand។ គាត់មិនបានទទួលឯកសារ D5/2/3 នោះទេ។

៣. អនុលោមតាមវិធានផ្ទៃក្នុង (**វិធាន**) ៧៧*ស្ទួន* (វិសោធនកម្មលើកទី៧) សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងដាក់បណ្តឹងឧទ្ធរណ៍សង្ខេបជួសមុខឲ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី(**បណ្តឹងឧទ្ធរណ៍**)។ សេចក្តីជូនដំណឹងពីបណ្តឹងឧទ្ធរណ៍នេះត្រូវបានដាក់ជូន

[1] នៅថ្ងៃទី៩ ឧសភា ២០១១ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេតលើកឡើងថា ការបដិសេធចំនួន ០២ ត្រូវបានធ្វើឡើងគឺ D11/2/3 សម្រាប់សំណុំរឿង ០០៣ និង D5/2/3 សម្រាប់សំណុំរឿង ០០៤។ ឯកសារ D11/2/3 ត្រូវបានទទួលដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមសំបុត្រប្រៃសនីយ។ ក្នុងកំឡុងពេលនោះដែរ ឯកសារ D5/2/3 មិនត្រូវបានទទួលដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឬមេធាវីរបស់គាត់ឡើយ។

រួចហើយ ដោយអនុលោមតាមវិធាន៧៥[2]។

៤. សារណានេះគឺជាសំណើដំបូងពាក់ព័ន្ធនឹងសិទ្ធិមើលសំណុំរឿង០០៣ និងសំណុំរឿង០០៤ របស់មេធាវីនៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ នៅថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០១១ មេធាវីអន្តរជាតិរបស់លោក HAMILL បានស្នើសុំសិទ្ធិមើលសំណុំរឿងក្តី។ មកទល់ពេល បច្ចុប្បន្ននេះ នៅមិនទាន់បានទទួលការអនុញ្ញាតឲ្យពិនិត្យមើលសំណុំរឿងក្តី០០៣ នៅឡើយទេ[3]។

៥. នៅក្នុងសារណានេះ យើងខ្ញុំសូមស្នើឲ្យចៅក្រមអង្គបុរេជំនុំជម្រះ អនុវត្តឆន្ទានុសិទ្ធដើម្បីពន្យារកាលបរិច្ឆេទកំណត់ក្នុងការដាក់បណ្តឹងឧទ្ធរណ៍ក្នុងអំឡុងពេលមួយសមស្រប(ដូចជា រយៈពេល៣០ថ្ងៃ) បន្ទាប់ពីអ្នកតំណាងផ្លូវច្បាប់របស់ភាគីដាក់បណ្តឹងឧទ្ធរណ៍បានទទួលសិទ្ធមើលសំណុំរឿងក្តីក្នុងសំណុំរឿងក្តី០០៣ ដើម្បីនឹងអាចធ្វើការវិភាគ និងបង្ហាញអំពីអង្គហេតុ អង្គច្បាប់ និងឯកសារដទៃទៀតនៅក្នុងបណ្តឹងឧទ្ធរណ៍។

៦. សំណើនេះត្រូវបានរៀបចំឡើងដោយផ្អែកលើវិធាន២៣*ស្ទួន* នៃវិធានផ្ទៃក្នុង ដែលចែងថា៖ "លើកលែង និងលុះត្រាតែ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានបដិសេធចោល អ្នកដាក់

---

[2] សេចក្តីជូនដំណឹងពីបណ្តឹងឧទ្ធរណ៍ ដាក់ជូននៅថ្ងៃទី១៦ ខែមេសា ឆ្នាំ ២០១១ របស់សហមេធាវី សំ សុគង់ និង Lyma NGUYEN។ នៅពេលដាក់ជូនបណ្តឹងឧទ្ធរណ៍នេះ នៅមិនទាន់មានលេខសម្គាល់ឯកសារនៅឡើយទេ។

[3] អ៊ីមែលរបស់លោកស្រី Lyma NGUYEN មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ផ្ញើជូនក្រឡាបញ្ជីសហចៅក្រមស៊ើបអង្កេត ក្រោមប្រធានបទ៖ "សំណើសុំសិទ្ធិមើលសំណុំរឿងក្តីនៅក្នុងសំណុំរឿងក្តី០០៣ និងសំណុំរឿងក្តី០០៤" ចុះកាលបរិច្ឆេទ ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០១១។ នៅថ្ងៃទី ៤ ខែ ឧសភា បុគ្គលិកនៃការិយាល័យសហចៅក្រមស៊ើបអង្កេត បាននិយាយថា ពួកគេមិនអាចជួយជ្រោមជ្រែងចាត់ចែងសំណើនេះឲ្យមានប្រសិទ្ធិភាពនោះទេ។ នៅថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១១ លោកស្រី NGUYEN បានសរសេរលិខិតមួយដោយផ្ទាល់ ផ្ញើជូនសហចៅក្រមស៊ើបអង្កេត និងនៅថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១ ការជួបប្រាស្រ័យទំនាក់ទំនងអំពីការងារនេះ បន្តមកទៀត ក៏បានធ្វើឡើង។

ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចអនុវត្តសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណីបាន”។

៧. ដោយសារតែបញ្ហានីតិវិធីជាមូលដ្ឋាន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនអាចអនុវត្តសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណីឲ្យបានត្រឹមត្រូវទេ លុះត្រាតែពួកគាត់បានទទួលសិទ្ធិមើលសំណុំរឿងក្តី ដើម្បីឲ្យពួកគាត់បានដឹងពីវិសាលភាពនៃការស៊ើបអង្កេត ចរិត និងអត្តសញ្ញាណរបស់ជនល្មើសដែលរងការចោទប្រកាន់ទាំងនោះ។ នៅក្នុងសំណុំរឿងក្តី០០២ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានទទួលសិទ្ធិមើលសំណុំរឿងក្តីនៅមុនពេលមានការបដិសេធ និងនៅក្នុងស្ថានភាពដែលអត្តសញ្ញាណរបស់ជនត្រូវចោទ ព្រមទាំងវិសាលភាពនៃការស៊ើបអង្កេត ត្រូវបានលាតត្រដាងជាសាធារណៈ[4]។

៨. សំណើនេះត្រូវបានរៀបចំឡើងដើម្បីជាប្រយោជន៍យុត្តិធម៌ និងដោយផ្អែកលើភាពត្រឹមត្រូវនៃនីតិវិធី ដោយសារអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនអាចរៀបចំមូលដ្ឋានអង្គហេតុ និង/ឬមូលដ្ឋានផ្លូវច្បាប់ប្រកបទៅដោយអត្ថន័យសម្រាប់បណ្តឹងឧទ្ធរណ៍បានទេ បើគ្មានការយល់ដឹងពីបញ្ហាជាមូលដ្ឋាននានាដែលពាក់ព័ន្ធនឹងសំណុំរឿងក្តីទេនោះ។

៩. លើសពីនេះទៀត កាលបរិច្ឆេទផុតកំណត់សម្រាប់ការដាក់សំណើស្នើឲ្យមានកិច្ចស៊ើបសួរនេះគឺរយៈពេលចំនួន១៥ថ្ងៃបន្ទាប់ពីការប្រកាសបិទការស៊ើបសួរ[5]។ សហមេធាវីតំណាងដើមបណ្តឹង

---

[4] សូមមើល “សេចក្តីថ្លែងការណ៍” របស់ ការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ តាមរយៈអាសយដ្ឋាន http://www.eccc.gov.kh/english/cabinet/press/138/ECCC_Press_Release_5_Nov_2009_Eng.pdf.

[5] កាលបរិច្ឆេទផុតកំណត់ មានសុពលភាពត្រឹមថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ដោយអនុលោមតាមនីតិវិធីក្រោមវិធាន៣៩(៣) នៃវិធានផ្ទៃក្នុង ដោយមិនគិតពីថ្ងៃឈប់សម្រាកជាសាធារណៈនៅប្រទេសកម្ពុជានោះទេ។

រដ្ឋប្បវេណីសូមស្នើថា ការអនុវត្តសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណីឲ្យបានពេញលេញ ដូចជា សិទ្ធិស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមនេះ មិនអាចប្រព្រឹត្តទៅបានទេ ប្រសិនបើមិនមានការអនុញ្ញាតឲ្យពិនិត្យមើលសំណុំរឿងក្តីនោះ។

១០. វិធាន២១(គ) នៃវិធានផ្ទៃក្នុងបានចែងដោយជាក់លាក់ថា៖ “អង្គជំនុំជម្រះវិសាមញ្ញ ត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរនីតិវិធីរឿងក្តី”

១១. ការបដិសេធបណ្តឹងរដ្ឋប្បវេណី ដោយមិនបានផ្តល់ឲ្យអ្នកដាក់ពាក្យសុំនូវសិទ្ធិក្នុងការយល់ដឹងពីមូលហេតុសំខាន់ៗនៃការបដិសេធ ព្រមទាំងបង្កើតនូវទឡ្ហីករណ៍ឲ្យបានត្រឹមត្រូវ ដើម្បីគាំទ្រដល់បណ្តឹងឧទ្ធរណ៍នោះ គឺជាការប្រព្រឹត្តផ្ទុយទៅនឹងគោលការណ៍ និងការធានាយុត្តិធម៌អន្តរជាតិនានាដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ ដូចជា វិធាន២១នៃវិធានផ្ទៃក្នុងដែលត្រូវអនុវត្តដើម្បីធាននូវសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព។ វាក៏ជាការរំលោភទៅលើគោលការណ៍ជាមូលដ្ឋានស្តីពីយុត្តិធម៌របស់ជនរងគ្រោះពីឧក្រិដ្ឋកម្ម និងការរំលោភអំណាច[6]។

១២. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏ស្នើការអនុញ្ញាតដើម្បីដាក់ទឡ្ហីករណ៍ផ្នែកអង្គហេតុ និងអង្គច្បាប់បន្ថែមទៀត នៅពេលណាមួយសមស្រប បន្ទាប់ពីទទួលបានការអនុញ្ញាតឲ្យមើលសំណុំ

[6] សេចក្តីប្រកាសស្តីពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះពីឧក្រិដ្ឋកម្ម និងការរំលោភអំណាច អនុម័តដោយមហាសន្និបាទអង្គការសហប្រជាជាតិនៅក្នុងសេចក្តីសេចក្តីសម្រេចលេខ ៤០/៣៤ ថ្ងៃទី២៩ វិច្ឆិកា ១៩៨៥។

រឿងក្ដីរួចមក។

១៣. ដោយយោងលក្ខណៈសង្ខេបនៃបណ្ដឹងឧទ្ធរណ៍ (ដែលនឹងត្រូវដាក់ជូនអោយបានមុនថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១១) នោះយើងខ្ញុំសូមគោរពស្នើសុំឲ្យអង្គបុរេជំនុំជម្រះផ្ដល់នូវការឆ្លើយតបចំពោះសំណើនេះឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

## សេចក្ដីសន្និដ្ឋាន

១៤. សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សូមដាក់ជូនសំណើខាងក្រោមដោយក្ដីគោរពចំពោះចៅក្រមអង្គបុរេជំនុំជម្រះ ៖

ក. ប្រកាសទទួលយកសំណើនេះ និង

ខ. អនុវត្តឆន្ទានុសិទ្ធដោយយល់ព្រមពន្យារកាលបរិច្ឆេទកំណត់សម្រាប់បណ្ដឹងឧទ្ធរណ៍ជំទាស់នឹងសេចក្ដីសម្រេចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និង/ឬ

គ. អនុញ្ញាតឲ្យអ្នកតំណាងផ្លូវច្បាប់របស់ភាគីប្ដឹងឧទ្ធរណ៍ ដាក់ជូនទឡ្ហីករណ៍ផ្នែកអង្គហេតុ និងអង្គច្បាប់បន្ថែមទៀតនៅពេលមួយសមស្របបន្ទាប់ពីទទួលបានការអនុញ្ញាតឲ្យមើលសំណុំរឿង។

សូមដាក់ជូនដោយគោរពពី

| | |
|---|---|
| លោក សំ សុគង់ | លោកស្រី Lyma NGUYEN |
| សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីជាតិ | សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអន្តរជាតិ |

ចុះហត្ថលេខានៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០១១។